ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
សាលាខេត្តកណ្ដាល

លេខ:...០០៥.......ស.ស.រ

កណ្ដាល, ថ្ងៃទី ០៩ ខែមករា ឆ្នាំ២០១៥

# សេចក្ដីសម្រេច
# ស្ដីពី
# ការកែសម្រួលសមាសភាពគណៈកម្មការចម្រុះ គ្រប់គ្រងការធ្វើអាជីវកម្មខ្សាច់

## អភិបាលខេត្តកណ្ដាល

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៦៣ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីការតែងតាំងអភិបាលនៃគណៈអភិបាលខេត្តកណ្ដាល។
- បានឃើញប្រកាសលេខ ៤២៧៤ ប្រ.ក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ស្ដីពីការ បង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយាល័យនៃសាលាស្រុក និង ការកំណត់តួនាទីភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ។
- យោងលិខិតលេខ ១១៤៩ ធទឧ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៦ របស់ក្រសួងធនធានទឹក និង ឧតុនិយម។
- យោងសេចក្ដីសម្រេចលេខ ១០៦ ស.ស.រ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៣ របស់សាលាខេត្តកណ្ដាល ស្ដីពីការកែសម្រួលសមាសភាពគណៈកម្មការចម្រុះគ្រប់គ្រងការធ្វើអាជីវកម្មខ្សាច់។
- យោងតាមការងារចាំបាច់របស់រដ្ឋបាលខេត្ត។

## <u>សម្រេច</u>

**ប្រការ១៖** ត្រូវបានកែសម្រួលសមាសភាពគណៈកម្មការចម្រុះគ្រប់គ្រងការធ្វើអាជីវកម្មខ្សាច់ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តម ជឹម សុខខុន | អភិបាលរងខេត្ត | ប្រធាន |
| ២-លោក ជុន ម៉េងឡុង | ប្រធានមន្ទីរធនធានទឹក និង ឧតុនិយមខេត្ត | អនុប្រធានប្រចាំការ |
| ៣-លោក ចក់ គង់ | ប្រធានមន្ទីររ៉ែ និង ថាមពលខេត្ត | អនុប្រធាន |
| ៤-លោក អ៊ូម ឆារ៉ាត់ | ប្រធានមន្ទីរបរិស្ថានខេត្ត | អនុប្រធាន |
| ៥-ឧត្តមសេនីយ៍ត្រី អ៊ិច ចំរើន | ស្នងការនគរបាលខេត្ត | សមាជិក |
| ៦-ឧត្តមសេនីយ៍ត្រី មាស សុវណ្ណា | មេបញ្ជាការកងរាជអាវុធហត្ថខេត្ត | សមាជិក |
| ៧-លោក ម៉ឹង យូឡេង | ប្រធានមន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត | សមាជិក |
| ៨-លោក លឹម គឹមនី | នាយកទីចាត់ការអន្តរវិស័យសាលាខេត្ត | សមាជិក |
| ៩-លោក អ៊ុក វណ្ណា | អនុប្រធានមន្ទីរធនធានទឹក និង ឧតុនិយមខេត្ត | សមាជិក |
| ១០-លោក ខាង ប៊ុណ្ណារ៉ា | អនុប្រធានមន្ទីររ៉ែ និង ថាមពលខេត្ត | សមាជិក |

| | | | |
|---|---|---|---|
| ១១-លោក | ពុជ សុផល | អនុប្រធានមន្ទីររ៉ែ និង ថាមពលខេត្ត | សមាជិក |
| ១២-លោក-លោកស្រី | អភិបាលក្រុង-ស្រុក ដែលមានភូមិសាស្ត្រពាក់ព័ន្ធ | | សមាជិក |
| ១៣-លោក | ភុយ ឆុន | ប្រធានការិ.កិច្ចការច្បាប់ និង សុវត្ថិភាពសាធារណៈសាលាខេត្ត | សមាជិក |
| ១៤-លោក | អុល ចាន់ណា | ប្រធានការិ.សេដ្ឋកិច្ច និង សង្គមកិច្ចសាលាខេត្ត | សមាជិក |
| ១៥-លោក | ទ៉ែន សុខន្នី | មន្ត្រីការិ.សេដ្ឋកិច្ច និង សង្គមកិច្ចសាលាខេត្ត | ជាលេខាធិការ |

**ប្រការ២៖** គណៈកម្មការចម្រុះខាងលើ មានភារកិច្ច និង ការទទួលខុសត្រូវ ដូចតទៅ៖

- ពិនិត្យគ្រប់គ្រងទីតាំងអាជីវកម្មខ្សាច់ ដែលបាននឹងកំពុងដំណើរការអនុវត្តឲ្យបានត្រឹមត្រូវតាមការកំណត់លក្ខណៈបច្ចេកទេសពីជំនាញធនធានទឹក និង ចំណុចមានចែងក្នុងអាជ្ញាប័ណ្ណដែលចេញដោយក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល។
- ធ្វើការសិក្សា និង គ្រប់គ្រងទីតាំងដេប៉ូស្តុកខ្សាច់ ផ្លូវ និង មធ្យោបាយដឹកជញ្ជូន ដើម្បីកាត់បន្ថយបាននូវផលប៉ះពាល់បរិស្ថាន ព្រមទាំងការខូចខាតផ្លូវ។
- ពិនិត្យបែបបទ និង សិក្សាពីទីតាំងចំពោះអាជីវកម្ម ដែលមានបំណងសុំអាជ្ញាប័ណ្ណធ្វើអាជីវកម្មថ្មី។
- មានវិធានការម៉ឺងម៉ាត់ចំពោះម្ចាស់អាជីវកម្ម ដែលអនុវត្តមិនបានត្រឹមត្រូវ ទាំងការបូម ការជីកយកខ្សាច់ ការស្តុកទុក ព្រមទាំងការដឹកជញ្ជូនដែលធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ បរិស្ថាន និងការរស់នៅរបស់ប្រជាពលរដ្ឋ។
- ប្រកាសសុពលភាពអាជ្ញាប័ណ្ណ និង ពិនិត្យចំណុចដែលត្រូវធ្វើអាជីវកម្មតាមអាជ្ញាប័ណ្ណ ដើម្បីអាជ្ញាធរមូលដ្ឋាន និង ប្រជាពលរដ្ឋបានដឹង នឹងចូលរួមសហការ។
- បញ្ឈប់សកម្មភាពអាជីវកម្មទាំងឡាយ ដែលបាននឹងកំពុងធ្វើអាជីវកម្ម ដែលមិនទាន់មាន ឬគ្មានអាជ្ញាប័ណ្ណ។
- គណៈកម្មការមានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទ និង ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។
- រាល់ភារកិច្ចខាងលើ ត្រូវរាយការណ៍ និងសុំយោបល់ ដឹកនាំពីឯកឧត្តម អភិបាលខេត្ត។

**ប្រការ៣៖** គ្រប់រដ្ឋបាលក្រុង-ស្រុក ត្រូវរៀបចំកែសម្រួលសមាសភាពអនុគណៈកម្មការចម្រុះគ្រប់គ្រងការធ្វើអាជីវកម្មខ្សាច់ក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន តាមរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុង-ស្រុកដែលមានសមាសភាព និង ភារកិច្ចប្រហាក់ប្រហែលនឹងគណៈកម្មការចម្រុះគ្រប់គ្រងការធ្វើអាជីវកម្មខ្សាច់របស់ខេត្ត។

**ប្រការ៤៖** សេចក្តីសម្រេចលេខ ១០៦ សសរ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៣ របស់រដ្ឋបាលខេត្តកណ្តាល ស្តីពីការកែសម្រួលសមាសភាពគណៈកម្មការចម្រុះគ្រប់គ្រងការធ្វើអាជីវកម្មខ្សាច់ ត្រូវបានចាត់ទុកជានិរាករណ៍។

**ប្រការ៥៖** នាយករដ្ឋបាលសាលាខេត្ត ប្រធានមន្ទីរ-អង្គភាពពាក់ព័ន្ធ លោកអភិបាលក្រុង -ស្រុកគ្រប់ស្រុក និង ឯកឧត្តមអស់លោកដូចមានរាយនាមក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

អភិបាលខេត្ត

ម៉ៅ ភិរុណ

***ចម្លងជូន:***

-ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
-ក្រសួងមហាផ្ទៃ
-គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ថ្នាក់ជាតិ
-ក្រសួងធនធានទឹក និង ឧតុនិយម
-ក្រសួងរ៉ែ និង ថាមពល
-ក្រសួងសាធារណការ និង ដឹកជញ្ជូន
-ក្រសួងបរិស្ថាន

*"ដើម្បីគោរពជូនជ្រាប"*

-ដូចប្រការ ៥ *"ដើម្បីអនុវត្ត"*
-ឯកសារ-កាលប្បវត្តិ